**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការដាក់អោយអនុវត្តគំរូទូទៅ លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ

««១»»

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីច្បាប់សហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពី ការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពី គោល ការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី

**<u>សំរេច</u>** :

**មាត្រា ១ :** គ្រប់ក្រសួង-ស្ថាប័ន ត្រូវរៀបចំក្របខ័ណ្ឌរបស់ខ្លួន និង រៀបរៀងលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌនិមួយៗទៅតាមបែបបទដែលកំណត់ដោយ ព្រះរាជក្រឹត្យ លេខជស /រកត/១២៩៧/២៧៣ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា ២ :** ក្នុងការរៀបរៀងលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌនិមួយៗក្រសួងត្រូវរៀបរៀងតាមខ្លឹមសាររាជក្រឹត្យគំរូស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ ដែលភ្ជាប់ជា ឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៨

| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
|---|---|
| **អ៊ឹង ហួត** | **ហ៊ុន សែន** |

<u>សូមជំរាបជូន</u> ៖

ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**ប្រាក់ សុខ**

**<u>កន្លែងទទួល</u>** ÷

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីទី ២
- គ្រប់ក្រសួងស្ថាប័ន-កណ្តាល
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ